

# ក្មេងស្រីដែលសើចមិនចេះឈប់

Let's Read
The Asia Foundation



សំណើចដ៏ក្អាកក្អាយមួយបានលាន់ឡើងនៅក្នុងថ្នាក់រៀន ទី៤ខ។ លោកគ្រូ កាន់ដាប៉ាន់ ជាគ្រូបង្រៀនគណិតវិទ្យា បានដឹងយ៉ាងច្បាស់ពីប្រភពនៃការផ្ទុះឡើងនៃសំណើចនេះ។ «ហាហាហាហាហាហាហាហា!!!»



ភ្លាមនោះ គាត់និយាយឡើងថា៖ «ដារី! សូមប្អូនចេញពីថ្នាក់រៀននេះទៅ» ។

ថ្នាក់រៀនស្រាប់តែប្រែជាស្ងៀមស្ងាត់ ហើយគ្រប់គ្នាសម្លឹងមើលទៅ ដារី ដែលអង្គុយនៅតុទី៥។



«ប៉ុន្តែ...លោកគ្រូ! ខ្ញុំសូមទោស! ខ្ញុំបានព្យាយាមទប់វាហើយ តែទប់មិនបាន!»

ពេលឮ ដារីនិយាយ គ្រប់គ្នានៅក្នុងថ្នាក់ទី ៤ ”ខ” ក៏នាំគ្នាផ្ទុះសំណើចឡើង។



ដារី ពូកែសើចណាស់។ នាងសើចស្ទើរតែគ្រប់រឿង។



ឧទាហរណ៍ កាលពីអាទិត្យមុន មិត្តរួមថ្នាក់ម្នាក់បានប្រាប់រឿងកំប្លែងមួយដល់ ដារី ៖ «ហេតុអ្វីបានជា លោកគ្រូគណិតតែងតែមានមុខក្រៀមក្រំ?»
ចម្លើយគឺ «ព្រោះតែគាត់ត្រូវដោះស្រាយលំហាត់ជាច្រើន»។
ដារី ធ្វើភ្នែកព្រឹមៗ ហើយសើចឃឹកៗ។ ហេតុនេះហើយទើបបានជាគ្រប់គ្នាសើច នៅពេលឃើញលោកគ្រូ កាន់ដាប៉ាន់។



រឿងកំប្លែងនីមួយៗ តែងតែធ្វើឱ្យ ដារី ផ្ទុះសំណើចផ្សេងៗគ្នា។
ពេលខ្លះ នាងសើចតិចៗបែបសុភាព៖ «ហេហេហេ។»
ពេលខ្លះ នាងសើចឃឹកៗ៖ «ហាហាហាហា។»
ពេលខ្លះ នាងសើចខ្លាំងៗ៖ «អាហាសហាសហាសហា។»



ពេលខ្លះនាងសើចខ្លាំងៗ លាន់ដូចសំឡេងយក្សា៖ «ហុហុសហុសហុសហុស។»
ជួនកាល នៅពេលដែលនាងប្រឹងទប់សំណើចរបស់នាងខ្លាំងពេកទៅ វាក៏លាន់ឡើងដូចសំឡេងគ្រាប់បែបផ្ទុះ៖ «អឹមមមមមមមមអាអាអាអាអាអាអាហាសហាសហាសហាសហាសហាសហាស !!!»



ដារី ពិបាកចិត្តណាស់។ តើនាងជាមនុស្សចម្លែកមែនទេ? ហេតុអ្វីបានជានាងទប់សំណើចមិនបានអីចឹង? នាងត្រូវតែធ្វើអ្វីម្យ៉ាង។

នាងបានព្យាយាមដាក់កន្សែងដៃក្នុងមាត់របស់នាង តែនៅតែមិនអាចឈប់សើចបាន។ ពេលនាងសើច កន្សែងដៃក៏ធ្លាក់ចេញពីមាត់នាង។



ដារី បានធ្វើបញ្ជីមួយពីរឿងដែលនាងគិតថាគួរឱ្យអស់សំណើច៖

៥. ការចាក់ក្រឡេក

៤. ពាក្យ«នំគ្រក់»

៣. មនុស្សរអិលដួលលើសម្បកចេក

២. រឿងកំប្លែងពីបង្គន់

១. សំឡេងផោម



ដារី បានសម្រេចចិត្តថា៖ «ខ្ញុំនឹងមិនសើចពីរឿងទាំងនេះទៀតទេ» ។



ស្អែកឡើង ពេលនៅបណ្ណាល័យ សិស្សច្បង ម៉ានី បានបញ្ចេញ
សំឡេងមួយនៅខាងក្រោយទូដាក់សៀវភៅ ក្រោយខ្នង ដារី
ឮតែ ពូត ពូត ពូតតតតតត ។
ដារី ស្គាល់សំឡេងផោមនេះច្បាស់ណាស់ នាងផ្ទុះសំណើច
ឡើង ភ្លេចអស់ពីបញ្ជីរបស់នាង!
នាងគិតថា បែបនេះមិនកើតទេ។ នាងត្រូវតែចាប់ផ្ដើមផែនការ
ទីពីរ។



ផែនការទីពីររបស់នាង គឺទៅជួប បងប្រុសរបស់នាងឈ្មោះ ពិសិដ្ឋ ដែលជាអ្នកវិទ្យាសាស្ត្រ។

នាងគិតថា គាត់ប្រហែលជាអាចបង្កើតម៉ាស៊ីន ដែលអាចជួយឱ្យនាងឈប់សើចបាន? នៅពេល ដារី ប្រាប់គាត់ពីអ្វីដែលរំខានចិត្តនាង  ពិសិដ្ឋ ដែលធម្មតាតែងតែមានទឹកមុខម៉ឺងម៉ាត់ បានផ្ទុះសំណើចឡើង។




ដារី ឆ្ងល់ថាតើនេះជាបញ្ហាតក្នុងគ្រួសារមែនទេ។ តើក្រុមគ្រួសាររបស់នាងមានជំងឺសើចដូចគ្នាទាំងអស់ឬ?

ពិសិដ្ឋ ពន្យល់ថា៖ «ទេ!វាជារឿងធម្មតាដែលមនុស្សយើងសើចពេលឮឬឃើញអ្វីមួយដែលគួរឱ្យអស់សំណើច។ គ្រាន់តែមានអ្នកខ្លះសើចច្រើនជាងអ្នកដទៃទៀតតែប៉ុណ្ណោះ ហើយវាជារឿងធម្មតាតើ។»




«ពិតមែន?» ស៊ុនដារី សួរបញ្ជាក់ ព្រោះនាងតែងតែត្រូវបានគេប្រាប់ថា នាងសើចច្រើនពេកហើយ។

ពិសិដ្ឋ ប្រាប់ប្អូនស្រីថា៖ «ការសើច គឺល្អចំពោះសុខភាព ព្រោះវាបានបញ្ចេញនូវសារធាតុគីមីម៉្យាងដែលធ្វើឱ្យយើងរីករាយ។»



ពិសិដ្ឋ សួរទៅកាន់នាងថា៖ « តើឯងដឹងទេ សូម្បីតែមនុស្ស
ជំនាន់មុនក៏សើចដែរ?»
ដារី ស្រមៃឃើញបុរសម្នាក់ដែលមានពុកចង្ការវែងៗ ហើយកាន់ដំ
បងធំៗ កំពុងសើចដូចនាង នៅក្នុងថ្នាក់គំនូរ។
«ហ្នឹងហើយ» ដារីនិយាយ។
«មនុស្សជំនាន់មុន ចេះសើចមុនពេលពួកគេមានភាសា
ទៅទៀត។ នេះវាជាវិធីដែលពួកគេបង្ហាញប្រាប់គ្នាថាគ្រប់យ៉ាង
គ្មានបញ្ហា។»



«សព្វថ្ងៃ យើងសើចដើម្បីបង្ហាញទៅអ្នកដទៃថាយើងចូលចិត្ត ពួកគេ ឬ បង្ហាញពីសុភមង្គលរបស់យើង។ ហើយសត្វក៏អាច សើចបានដែរណា ដូចជា សត្វស្វាឪ ស្វាធំ កណ្ដុរ ត្រីដូហ្វីន និង សូម្បីតែឆ្កែ!»

គ្រាន់តែឮពាក្យឆ្កែ ដារី ក៏នឹកដល់ឆ្កែចិញ្ចឹមរបស់នាងឈ្មោះ មូមូ ហើយនាងក៏ផ្ទុះសំណើច។



នៅពេលដែលសំណើចបានស្ងប់ទៅវិញ ពិសិដ្ឋ សួរថា៖ «តើឯងដឹងទេថា ឯងទើបតែបានហាត់ប្រាណទេ ដារី?»

«ហាត់យ៉ាងម៉េចទៅ? បើយើងកំពុងតែជជែកគ្នាហ្នឹង។»
«គឺនៅពេលដែលឯងសើចហ្នឹងហើយ សូម្បីតែបន្តិចក៏ដោយ សាច់ដុំមុខរបស់ឯងនឹងធ្វើចលនា។ ដូច្នេះ គ្រប់ពេលដែលឯងញញឹម ឬសើច មុខរបស់ឯងនឹងបានហាត់ប្រាណ»
«អូ! អ៊ីចឹងតើថ្ពាល់របស់ខ្ញុំនឹងឡើងប៉ោងដូចឡើងសាច់ដុំដើមដៃដែរទេ?»



ពិសិដ្ឋ ញញឹម៖ «ទេ! វាមិនមែនជាសាច់ដុំដើមដៃទេ។ ប៉ុន្តែ ពេលណាដែលឯងសើច សាច់ដុំថ្គាល់ធំតូចរបស់ឯង ធ្វើសកម្មភាពឡើងលើ បង្កើតឱ្យមានទឹកមុខញញឹម។»

«ចុះសំឡេងវិញនោះ? វាក៏ធ្វើឱ្យអ្នកផ្សេងទៀតសើចដែរ។» ដារី និយាយ។

«ពេលដែលឯងដកដង្ហើម ខ្យល់ចេញពីបំពង់បញ្ចេញសំឡេងរបស់ឯងទៅកាន់សួត។ ប៉ុន្តែពេលឯងសើច ខ្យល់នឹងថយក្រោយ នាំឱ្យចេញសំឡេងជាចង្វាក់ « ហា ហា ហា» ដែលឯងហាក់ដូចជាមិនអាចឈប់សើចបាន។» ពិសិដ្ឋ ពន្យល់។



« អ៊ីចឹង ដារី ឯងយល់ហើយមែនទេថាការសើចគឺជារឿងធម្មជាតិសុទ្ធសាធ? ដូច្នេះ ដរាបណាឯងមិនធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍អ្នកដទៃ ការសើចរបស់ឯងមិនខុសទាស់អីនោះទេ។»

ស្ដាប់សម្ដីរបស់ ពិសិដ្ឋ ហើយ ដារី ក៏មានអារម្មណ៍ល្អជាងមុន។



«ជិតដល់ម៉ោងផឹកតែហើយ។ យើងគួរតែញ៉ាំនំគ្រក់ដែរ ល្អទេ?» ពិសិដ្ឋ និយាយទាំងដឹងច្បាស់ថានឹងមានរឿងអ្វីកើតឡើងនៅពេលបន្ទាប់។ ដារី មិនអាចឈប់សើចបានទេ។ នាងមិនអាចឈប់សើចបាន បើទោះជានាងញ៉ាំនំគ្រក់ចូលទៅក្នុងពោះរបស់នាងអស់ទៅហើយក៏ដោយ។



តើអ្នកអាចសើចចេញជាសំឡេងទាំងនេះបានទេ?

សើចខ្លាំងៗដូចសំឡេងយក្សា - ហុហុ ហុស ហុស ហុស

សើចដូចផ្ទុះគ្រាប់បែក -អឹមមមមមអាអាអាហាហាហាហាហាហា

សើចដូចសំឡេងមេធ្មប់ - ហ៊ីហ៊ីហ៊ីហ៊ីហ៊ី

សើចឃឹកៗ- ហិហិហិហិហិហិ

សើចរលាក់ពោះ - ហ្អូហ្អូហ្អូហ្អូហ្អូហ្អូ

សើចស្ងួត - ហ៊ឺហ៊ឺហ៊ឺ

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Girl Who Could Not Stop Laughing*, Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Sivngim Nguon